# ១៧. ការណែនាំអំពី ការអនុវត្តន៍ផ្ទាល់នៅមូលដ្ឋាន

នៅថ្ងៃទីប្រាំនៃវគ្គបណ្តុះបណ្តាល សិក្ខាកាមគួរមានឱកាសអនុវត្តន៍នូវជំនាញដែលពួកគាត់បានរៀន។ អ្នកសម្របសម្រួលគួររៀបចំឱ្យមានការជួបប្រឹក្សានៅមូលដ្ឋាន ដើម្បីឱ្យសិក្ខាកាមបានហ្វឹកហាត់ផ្តល់ប្រឹក្សាពេញលេញជាមួយអ្នករស់នៅជាមួយមេរោគអេដស៍ យ៉ាងតិចម្នាក់ (ឬពីរនាក់ប្រសិនបើអាច)។ បើសិក្ខាកាមនឹងត្រូវធ្វើការជាមួយស្ត្រីមានផ្ទៃពោះ ឬស្ត្រីកំពុងបំបៅដោះកូន ឬកុមារ សូមធ្វើយ៉ាងណាឱ្យមានក្រុមគោលដៅនេះ១-២នាក់។ ការប្រឹក្សាជាមួយគ្រួសារនឹងមានប្រយោជន៍ច្រើនក្នុងការរៀនសូត្រសម្រាប់សិក្ខាកាម។

*ការពិចារណាទូទៅ៖*

1. គ្រប់ពេលធ្វើការជាមួយអ្នករស់នៅជាមួយមេរោគអេដស៍ (រួមទាំងការចុះអនុវត្តមេរៀនផង) ចាំបាច់ត្រូវតែការពារ និងគោរពភាពឯកជនរបស់ពួកគេ។ យើងហៅកញ្ចប់សម្ភារៈនេះថា "កញ្ចប់សម្ភារៈអាហារល្អ" និងមិនហៅថា "កញ្ចប់សម្ភារៈអាហារល្អសម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍"ទេ។ ពីព្រោះ អ្នកជិតខាង ឬអ្នកភូមិអាចនឹងចង់មើលសម្ភារៈ ឬស្តាប់លឺអំពីការប្រឹក្សា។ យើងចង់ឱ្យពួកគេដឹងត្រឹមតែថា វាជាការប្រឹក្សាអំពីអាហារល្អៗ និងការរស់នៅដោយសុខភាពល្អប៉ុណ្ណោះ។ លើកទឹកចិត្តឱ្យអ្នកជិតខាងចេញពីកន្លែងប្រឹក្សា ទៅធ្វើការងាររបស់ពួកគេ ដើម្បីផ្តល់ភាពឯកជនដល់បុគ្គល/គ្រួសារដែលទទួលការប្រឹក្សា។
2. អ្នកសម្របសម្រួលគួរតាមដានការអនុវត្តន៍របស់សិក្ខាកាមម្នាក់ៗ និងប្រើ "តារាងត្រួតពិនិត្យ"។ សូមប្រើ "តារាងត្រួតពិនិត្យ" មួយច្បាប់ សម្រាប់សិក្ខាកាមម្នាក់។
3. អ្នកសម្របសម្រួលអាចផ្តល់មតិជាក់លាក់ដល់សិក្ខាកាមដែលកំពុងអនុវត្តការប្រឹក្សា បើចាំបាច់ ដើម្បីឱ្យមានដំណើរការទៅមុខតាមលំដាប់លំដោយ។ ប៉ុន្តែត្រូវទុកឱ្យសិក្ខាកាមជាអ្នកដឹកនាំការប្រឹក្សា ដោយមិនត្រូវលូកដៃចូល និងដឹកនាំការប្រឹក្សាដោយខ្លួនឯងឡើយ ពីព្រោះធ្វើដូច្នេះនឹងមិនផ្តល់ឱកាសឱ្យសិក្ខាកាមបានរៀនសូត្រទេ។ ចំពោះមតិកែលម្អទូទៅវិញ សូមទុកប្រាប់ដល់សិក្ខាកាមនៅពេលបញ្ចប់ការប្រឹក្សា។
4. អ្នកសម្របសម្រួលគួររំលឹកឡើងវិញនូវតារាងត្រួតពិនិត្យជាមួយសិក្ខាកាមនៅមុនពេលរៀបចំការអនុវត្តនៅមូលដ្ឋាន។ ធ្វើបែបនេះ សិក្ខាកាមនឹងដឹងពីអ្វីដែលពួកគេគួរធ្វើ។
5. បន្ទាប់ពីចប់ការប្រឹក្សា អ្នកសម្របសម្រួលគួរពិនិត្យតារាងត្រួតពិនិត្យជាមួយសិក្ខាកាម ដើម្បីឱ្យសិក្ខាកាមមើលឃើញអំពីចំនុចគួរកែលម្អរបស់គាត់។
6. រៀបចំការអនុវត្តនៅពេលព្រឹក។ នៅពេលរសៀលថ្ងៃដដែល ពិភាក្សាជាមួយសិក្ខាកាមអំពីបទពិសោធន៍របស់ពួកគេ។ អ្នកអាចប្រើសំណួរខាងក្រោម៖
   - ពេលប្រើកញ្ចប់សម្ភារៈអាហារល្អពេលអនុវត្តជាក់ស្តែង តើមានភាពងាយស្រួល ឬលំបាក? ហេតុអ្វី?
   - ពេលបំពេញទម្រង់តាមដាននៅក្នុងពេលអនុវត្តជាក់ស្តែង តើមានភាពងាយស្រួល ឬលំបាក? ហេតុអ្វី?
   - តើមានចំនុចថ្មីណាមួយ ដែលអ្នកបានរៀននៅពេលអនុវត្តនៅមូលដ្ឋាន តែមិនបានរៀនក្នុងវគ្គឬទេ?
   - តើអ្នកគិតថា នឹងមានឧបសគ្គអ្វីក្នុងការប្រើកញ្ចប់សម្ភារៈអាហារល្អនៅថ្ងៃអនាគត? តើមាននរណាមានយោបល់អ្វីដើម្បីយកឈ្នះឧបសគ្គនេះទេ?
7. បន្ទាប់ពីសាកសួររួច អ្នកសម្របសម្រួលគួររៀបចំ "ពិធីប្រគល់វិញ្ញាបនបត្រ" តូចមួយ និងផ្តល់វិញ្ញាបនបត្រជូនដល់គ្រប់សិក្ខាកាមទាំងអស់។ អបអរសាទរចំពោះចំណេះដឹង និងជំនាញថ្មីរបស់ពួកគាត់ និងជូនពរពួកគាត់ឱ្យមានសំណាងល្អ ក្នុងការបំពេញការងារនាថ្ងៃអនាគត។

# បញ្ជីត្រួតពិនិត្យសម្រាប់ការវាយតម្លៃអាហារូបត្ថម្ភ និងការប្រឹក្សា

បញ្ជីត្រួតពិនិត្យខាងក្រោមនេះអាចត្រូវបានប្រើប្រាស់សម្រាប់លើកទឹកចិត្ត តាមដាន និងកែលម្អគុណភាពនៃការវាយតម្លៃអាហារូបត្ថម្ភ និងការប្រឹក្សា។ អ្នកគ្រប់គ្រងអាចប្រើប្រាស់បញ្ជីនេះសម្រាប់ផ្តល់មតិកែលម្អសម្រាប់អ្នកផ្តល់ប្រឹក្សា ឬអ្នកប្រឹក្សាក៏អាចប្រើប្រាស់សម្រាប់វាយតម្លៃខ្លួនឯង ឬវាយតម្លៃសហការីរបស់ខ្លួនទៅវិញទៅមក។

ឈ្មោះអ្នកប្រឹក្សា៖ ______________________ មុខនាទី៖ ______________________

ឈ្មោះអ្នកគ្រប់គ្រង/សហការី៖ ______________________

ទីកន្លែង៖ ______________________ កាលបរិច្ឆេទនៃការអង្កេត៖ ____________________

ប្រភេទអតិថិជន (សូមគូសនៅក្នុងប្រអប់សមស្រប)៖

- ☐ មនុស្សពេញវ័យ
- ☐ មានផ្ទៃពោះ
- ☐ ស្ត្រីសម្រាលកូនរួចបានក្នុងអំឡុង៦ខែ៖ ☐ បំបៅដោះកូន ☐ មិនបំបៅដោះកូន
- ☐ ស្ត្រីបំបៅដោះកូន សម្រាលកូនរួចបានលើសពី៦ខែ
- ☐ ទារកអាយុ ០–៦ខែ
- ☐ កុមារអាយុ ៦–៥៩ខែ
- ☐ កុមារអាយុ ៥–១៩ឆ្នាំ

សូមគូសនៅក្នុងប្រអប់សមស្រប៖

| | មិនធ្វើ | ធ្វើមិនបានសម្រេច | សម្រេចបានខ្លះ | សម្រេចបានល្អ | មតិយោបល់ |
|---|---|---|---|---|---|
| **តើអ្នកប្រឹក្សា/ សហការីរបស់អ្នក/ អ្នក...** | | | | | |
| **ការរៀបចំ និងការណែនាំ** | | | | | |
| បានរាក់ទាក់អ្នករស់នៅជាមួយមេរោគអេដស៍/កុមារ/កុមារកំព្រា និងងាយរងគ្រោះ និងក្រុមគ្រួសារពួកគេដែរទេ? | | | | | |
| បានពន្យល់ពីគោលបំណងនៃការជួបប្រឹក្សានេះទៅអ្នកផ្ទុកមេរោគអេដស៍ និងគ្រួសារដែរទេ? | | | | | |
| បានបំពេញព័ត៌មាននៅក្នុងប្រអប់បីដំបូងនៅទំព័រមុខនៃទម្រង់តាមដានបានទាំងអស់ និងត្រឹមត្រូវដែរឬទេ? | | | | | |
| បានកំណត់សន្ទស្សន៍ម៉ាស់រាងកាយ និងការស្រកទម្ងន់នាពេលថ្មីៗនេះ(ប្រសិនបើមាន) បានត្រឹមត្រូវដែរឬទេ? | | | | | |

| | មិនធ្វើ | ធ្វើមិនបានសម្រេច | សម្រេចបានខ្លះ | សម្រេចបានល្អ | មតិយោបល់ |
|---|---|---|---|---|---|
| **តើអ្នកប្រឹក្សា/ សហការីរបស់អ្នក/ អ្នក...** | | | | | |
| **ការវាយតម្លៃ និងវិភាគ** | | | | | |
| **ការវាយតម្លៃសុខភាព និងអាហារូបត្ថម្ភ** | | | | | |
| បានវាយតម្លៃសញ្ញានៃជំងឺ និងការឆ្លងរោគរបស់អតិថិជនត្រឹមត្រូវដែរទេ? | | | | | |
| បានរកឃើញមានការថយទម្ងន់របស់អតិថិជនទេ? (បើមាន) | | | | | |
| **រង្វាស់រាងកាយ** (សូមជ្រើសរើសសំណួរសមស្របទៅតាមប្រភេទអតិថិជន) | | | | | |
| *មនុស្សពេញវ័យ គ្មានផ្ទៃពោះ* | | | | | |
| បានថ្លឹងទម្ងន់ និងវាស់កម្ពស់ ត្រឹមត្រូវឬទេ? | | | | | |
| បានគណនា BMI និងបកស្រាយត្រឹមត្រូវឬទេ? | | | | | |
| *ស្ត្រីមានផ្ទៃពោះ និងស្ត្រីសម្រាលកូនរួចក្នុងអំឡុង៦ខែ ឬកុមារអាយុ៦–៥៩ឆ្នាំ* | | | | | |
| បានវាស់វែង MUAC និងបកស្រាយបានត្រឹមត្រូវឬទេ? | | | | | |
| *កុមារ ឬក្មេងជំទង់អាយុ ៥–១៩ឆ្នាំ* | | | | | |
| បានថ្លឹងទម្ងន់ និងវាស់កម្ពស់ ត្រឹមត្រូវឬទេ? | | | | | |
| *ទារកអាយុ ០–៦ខែ* | | | | | |
| បានពិនិត្យមើលភាពហើម ត្រឹមត្រូវឬទេ? | | | | | |
| បានវាតម្លៃ និងបែងចែកស្ថានភាពអាហារូបត្ថម្ភត្រឹមត្រូវឬទេ? | | | | | |
| **ការវាយតម្លៃលើការបរិភោគអាហារ** | | | | | |
| វាយតម្លៃ និងសន្និដ្ឋានត្រឹមត្រូវអំពី អាហារ អាហារសម្រន់ និងសារធាតុរាវដែលអតិថិជនបរិភោគប្រចាំថ្ងៃ? | | | | | |
| វាយតម្លៃ និងសន្និដ្ឋានត្រឹមត្រូវអំពី កម្រិត/ចំនួនដងនៃការបរិភោគអាហារ អាហារសម្រន់ និងសារធាតុរាវ? | | | | | |
| **ការផ្លាស់ប្តូរឥរិយាបថ និងការតាមដាន** | | | | | |
| ប្រើប្រាស់ភាសាកាយវិការបានល្អ? | | | | | |
| ស្តាប់អតិថិជនដោយយកចិត្តទុកដាក់? | | | | | |
| ស្វែងរកឃើញការលំបាកធំៗ (បើមាន) និងពិភាក្សាជាមួយអតិថិជនអំពីដំណោះស្រាយ? | | | | | |

| | មិនធ្វើ | ធ្វើមិនបានសម្រេច | សម្រេចបានខ្លះ | សម្រេចបានល្អ | មតិយោបល់ |
|---|---|---|---|---|---|
| **តើអ្នកប្រឹក្សា/ សហការីរបស់អ្នក/ អ្នក...** | | | | | |
| ផ្តល់អនុសាសន៍ និងចរចារអំពីសកម្មភាពដែលអាចធ្វើបាន និងជួយអតិថិជនក្នុងការជ្រើសរើសជម្រើសប្រសើរបំផុត សមស្របទៅតាមបរិបទ និងធនធានរបស់ពួកគេ? | | | | | |
| ផ្តល់ឱកាសឱ្យអតិថិជនសួរសំណួរ និងឆ្លើយតបដោយសមរម្យ? | | | | | |
| បានកំណត់ពេលវេលាជួបតាមដានពេលក្រោយ? | | | | | |
| **ការប្រើប្រាស់សម្ភារៈជំនួយ** | | | | | |
| ប្រើប្រាស់ប័ណ្ណអាហារតូចត្រឹមត្រូវ ក្នុងការវាយតម្លៃឬទេ? | | | | | |
| ប្រើប្រាស់ប័ណ្ណអាហារធំត្រឹមត្រូវ ក្នុងការវាយតម្លៃឬទេ? | | | | | |
| ប្រើប្រាស់ប័ណ្ណអាហារតូចត្រឹមត្រូវ ក្នុងការចរចារ និងជ្រើសរើសសកម្មភាពដែលត្រូវផ្លាស់ប្តូរឬទេ? | | | | | |
| ប្រើប្រាស់ប័ណ្ណអាហារធំត្រឹមត្រូវ ក្នុងការចរចារ និងជ្រើសរើសសកម្មភាពដែលត្រូវផ្លាស់ប្តូរឬទេ? | | | | | |
| ប្រើប្រាស់ប័ណ្ណរស់នៅដោយវិជ្ជមានបានសមស្របនៅពេលផ្តល់ប្រឹក្សា ស្របទៅតាមស្ថានភាពរបស់អតិថិជន? | | | | | |